# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥៨

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធធមិ ដើម្បីបំពេញបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ លើវិស័យច្បាប់ និងយុត្តិធមិ ហើយដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ឌិត មន្ទី** ប្រធានតុលាការកំពូល ជាសហប្រធាន

២-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដមន្រ្តី ជាសហប្រធាន

៣- ឯកឧត្តម **នាវ ស៊ីថុង** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ជាអនុប្រធាន

៤ - លោកជំទាវ **លី វួចឡេង** ប្រធានសាលាឧទ្ធរណ៍ ជាអនុប្រធាន

៥- ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសមាជិក

៦- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៧- ឯកឧត្តម **សុក ស៊ីផាន់ណា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

៨- ឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ២.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ មានទីតាំងស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានបេសកកម្ម ផ្តួចផ្តើម ជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តនយោបាយ និងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៤.-**

ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

សមាជិកនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវមានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍មួយ ជាអ្នកសំរបសំរួលដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាមួយស្ថាប័នរដ្ឋ និងស្ថាប័នអន្តរជាតិនានា ដែលពាក់ព័ន្ធ ។

**មាត្រា ៧.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្តលេខា លេខ : ១៤៤ ច ល

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

ដើម្បីចម្លងចែក

*រាជធានីភ្នំពេញ. ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**